ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៥៨០

ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣

សាលក្រមលេខ៖ ១៧ "ខ"

ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

## សាលក្រមរដ្ឋប្បវេណី

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

- **ដើមចោទ៖** ឈ្មោះ [redacted] ម៉ារ៉ាំ ភេទស្រី អាយុ ៣២ឆ្នាំ (កើតឆ្នាំ១៩៩១) ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន [redacted] ។

អ្នកតំណាងដោយអាណត្តិ លោក [redacted] សមាជិកគណៈមេធាវី ។

- **ចុងចម្លើយ៖** ឈ្មោះ [redacted] វន ភេទប្រុស អាយុ ៣៦ឆ្នាំ (កើតឆ្នាំ១៩៨៧) ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ។

**<u>អង្គហេតុ និងការទាមទាររបស់គូភាគី</u>**

**១- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ÷**

១.១- សុំលែងលះពីឈ្មោះ [redacted] វន ចាប់ពីពេលនេះតទៅ

១.២- សុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូនចំនួន ០២នាក់ (កូនទី១- ឈ្មោះ [redacted] គីមហួរ ភេទស្រី កើតថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ [redacted] បីហួង ភេទប្រុស កើតថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ ។

១.៣- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

**២- ការពន្យល់ត្រួសអំពីរឿងក្ដី ÷**

ដើមចោទ និងចុងចម្លើយ បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ១៥៦ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល ។ ក្រោយពីបានរួមរស់ជាប្ដីប្រពន្ធនឹងគ្នា ដើមចោទ និងចុងចម្លើយមានកូនចំនួន ០២នាក់ កូនទី១ ឈ្មោះ ឈ្មោះ [redacted] គីមហួរ ភេទស្រី កើតថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ និងកូនទី២ ឈ្មោះ [redacted] លីហួង ភេទប្រុស កើតថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ ។ ចំពោះទ្រព្យសម្បត្តិក្រោយពីរួមរស់ជាប្ដីប្រពន្ធ ដើមចោទ និងចុងចម្លើយមិនមានទ្រព្យសម្បត្តិរួមនោះទេ ចំណែកឯបំណុលជំពាក់គេ ឬគេជំពាក់ក៏គ្មានដែរ ។ ដើមចោទសុំលែងលះពីចុងចម្លើយ



Scanned with CamScanner

ដោយសារចុងចម្លើយបានចុះចោលខ្លួនតាំងពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ហើយកន្លងមកក្នុងការរស់នៅជាប្តីប្រពន្ធ មិនមានការចុះសម្រុងនឹងគ្នាទេ ធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ជាមួយចុងចម្លើយតទៅទៀតហើយ ទើបដើមចោទដាក់ពាក្យបណ្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] វន ។ ចំពោះសិទ្ធិអំណាចមេបាលើកូន នៅពេលកូនឈ្មោះ [redacted] លីហ្សុង កើតមកភ្លាម ចុងចម្លើយបានចុះចោលដើមចោទតែម្តង ទុកឱ្យដើមចោទមើលថែកូនទាំងពីរតែម្នាក់ឯង ។ ក្រោយពេលចុងចម្លើយចុះចោលដើមចោទ ចុងចម្លើយមិនដែលត្រឡប់មកវិញទេ និងមិនដែលផ្តល់អាហារកាតព្វកិច្ចចិញ្ចឹមកូនថែមទៀតផង មូលហេតុទាំងនេះហើយទើបដើមចោទសុំសិទ្ធិមានអំណាចមេបាលើកូនទាំងពីរនាក់ ។

**៣- ការអះអាងរបស់គូភាគី ÷**

ដើមចោទឈ្មោះ [redacted] ម៉ារ៉ាំ បានថ្លែងការណ៍ថា នៅពេលនេះនាងខ្ញុំនៅតែរក្សាខ្លឹមសារ និងការទាមទារដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ របស់នាងខ្ញុំទុកជាបានការដដែល ។

- ចុងចម្លើយឈ្មោះ [redacted] វន (អវត្តមាន) ដោយតុលាការបានធ្វើការកោះហៅត្រឹមត្រូវតាមច្បាប់ តែចុងចម្លើយអវត្តមានដោយពុំមានមូលហេតុ និងពុំបានដាក់ពាក្យស្នើសុំពន្យាពេលនោះទេ ។

មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ សុំធ្វើការកត់សម្គាល់ថា ក្នុងនាមមេធាវី ខ្ញុំបានយកដីកាកោះឱ្យអាជ្ញាធរឃុំសំបួរមាស ដើម្បីយកទៅឱ្យចុងចម្លើយរួចហើយ តែចុងចម្លើយពុំព្រមទទួលដីកាកោះរបស់តុលាការឡើយ ហើយនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៣ តុលាការបានបញ្ជូនដីកាកោះលើកទី២ ឱ្យទៅចុងចម្លើយតាមរយៈ Telegram ដែលមានលេខ០៨៦ ៨៨៩៩៨៥ ហើយចុងចម្លើយក៏បានឆ្លើយតបថាយល់ព្រមទទួលដំណឹង ជាមួយតុលាការហើយដែរ ប៉ុន្តែ បែរជានៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ គឺចុងចម្លើយនៅតែព្យាយាមគេចវេសមិនចូលខ្លួននោះឡើយ ដែលសកម្មភាពនេះ គឺចុងចម្លើយមានចេតនាអូសបន្លាយពេលវេលា និងបង្កការលំបាកដល់ដើមចោទជាប្រពន្ធ និងកូន ព្រោះចុងចម្លើយយល់ថា បើគេមិនចូលនោះតុលាការពុំអាចធ្វើអ្វីគេបាននោះទេ ។ ដូចនេះ ដើមចោទ និងខ្លួនដែលជាមេធាវី ស្នើសុំឱ្យតុលាការបន្តនីតិវិធី ដោយកុំឱ្យចុងចម្លើយមើលស្រាលការអនុវត្តច្បាប់បន្តទៀត ។

**៤- ចំណុចវិវាទ ÷**

តើការប្តឹងសុំរបស់ភាគីដើមចោទមានដូចនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ មានភាពត្រឹមត្រូវដែរ ឬទេ ?

**៥- ដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់ ÷**

ដើមចោទឈ្មោះ [redacted] ម៉ារ៉ាំ បានថ្លែងការណ៍ថា នៅពេលនេះនាងខ្ញុំនៅតែរក្សាខ្លឹមសារ និងការទាមទារដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ របស់នាងខ្ញុំ និងខ្លឹមសារនៃនីតិវិធីត្រៀមសម្រាប់ការតាញហេតុផលកាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ ទុកជាបានការដដែល ។

- ចុងចម្លើយឈ្មោះ [redacted] វន (អវត្តមាន) ដោយតុលាការបានធ្វើការកោះហៅត្រឹមត្រូវតាមច្បាប់ តែចុងចម្លើយអវត្តមានដោយពុំមានមូលហេតុ ។



Scanned with CamScanner

# <u>សំអាងហេតុ</u>

តាមលទ្ធផលនៃការសាកសួរគូភាគី និងពិនិត្យភស្តុតាង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១- ពាក្យបណ្ដឹង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ម៉ារ៉ា ជាដើមចោទ មានលក្ខណៈត្រឹមត្រូវ បញ្ជាក់ឱ្យឃើញថា សាលាដំបូងខេត្តកណ្ដាល មានដែនសមត្ថកិច្ចដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្ដឹង ហើយចេញសាលក្រមបានតាមបញ្ញត្តិមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា ៥ នៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ។

២- តាមការពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ [redacted] ម៉ារ៉ា ដែលមាននៅក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ក៏ដូចជា ខ្លឹមសារនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុ កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ដើមចោទឈ្មោះ [redacted] ម៉ារ៉ា នៅតែប្ដឹងទាមទារដូចក្នុងពាក្យបណ្ដឹងដដែល ។

៣- ចុងចម្លើយឈ្មោះ [redacted] វន មានទីលំនៅបច្ចុប្បន្នភូមិអន្លង់ស្វែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្ដាល (អវត្តមាន) នៅគ្រប់កិច្ចនីតិវិធីរបស់តុលាការ បើទោះបីជាតុលាការបានធ្វើការកោះហៅចុងចម្លើយ ព្រមទាំងបានធ្វើនីតិវិធីបញ្ជូនដីកាកោះ និងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តាមរយៈ Telegram ដែលមានលេខ ០៨៦ ៨៨៩៩៨៥ ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏ចុងចម្លើយមិនបានបង្ហាញខ្លួននៅគ្រប់កាលបរិច្ឆេទនៃនីតិវិធីរបស់តុលាការដែរ ហេតុនេះតុលាការសម្រេចបន្តនីតិវិធីព្រមទាំងចេញសាលក្រមចំពោះស្ថានភាព នៃសំណុំរឿងនេះ ដោយហេតុថា ចុងចម្លើយបានទទួល និងបានឃើញរាល់ការកោះហៅរបស់តុលាការគ្រប់កិច្ចនីតិវិធី គឺនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដោយតុលាការព្យាយាមគោរពនូវគោលការណ៍ចំពោះមុខ និងគោលការណ៍ស្វ័យភាពឆន្ទៈនៃបុគ្គលឯកជន ប៉ុន្តែចុងចម្លើយជាប្ដី គឺពុំមានចេតនា និងសុចរិតក្នុងនីតិវិធីបណ្ដឹងនោះឡើយ ដោយព្យាយាមបង្កការលំបាក និងការយឺតយូរដល់ភាគីដើមចោទជាប្រពន្ធ និងកូន ព្រមទាំងតុលាការ ដែលសកម្មភាពនៃចេតនានេះ គឺផ្ទុយទៅនឹងគោលការណ៍ដែលមានចែងក្នុងមាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ លើសពីនេះទៅទៀត ផ្អែកតាមអង្គហេតុនៃបណ្ដឹង មូលហេតុនៃការទាមទារលែងលះ និងភស្តុតាងនានាក្នុងសំណុំរឿង ព្រមទាំងស្ថានភាពជាក់ស្ដែង នៃសំណុំរឿងនេះ ធៀបទៅនឹងសកម្មភាពនៃបណ្ដឹងដែលចុងចម្លើយបានស្ដែងឡើង គប្បីតុលាការពិចារណាដោយឥស្សរចិត្តទៅលើភស្តុតាង និងអង្គហេតុនានា ដោយគោរពនូវគោលការណ៍ច្បាប់ និងឧត្តមប្រយោជន៍របស់ស្ត្រី និងកុមារ ។

៤- តាមសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ១៥៦ សៀវភៅអាពាហ៍ពិពាហ៍លេខ ០៤/២០២១ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសំបួរមាស អាចបញ្ជាក់បានថា ដើមចោទឈ្មោះ ធូ ម៉ារ៉ា និងចុងចម្លើយឈ្មោះ [redacted] វន គឺពិតជាប្ដី-ប្រពន្ធនឹងគ្នា ហើយដើមចោទបានអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយចុងចម្លើយតទៅទៀត ហើយ ដែលធ្វើអោយទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចផ្សះផ្សាឡើងវិញបាន គប្បីតុលាការពិចារណា និងសម្រេចទៅតាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

៥- តាមសំបុត្របញ្ជាក់កំណើតលេខ ៣៤៥ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០១៨ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] គីមហួរ ភេទស្រី និងសំបុត្រកំណើតលេខ ៦៣ សៀវភៅកំណើតលេខ ០២/២០២២ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] លីហួង ភេទប្រុស អាចបញ្ជាក់បានថា ដើមចោទ និងចុងចម្លើយ គឺជាឪពុកម្ដាយបង្កើតរបស់កូនទាំងពីរនាក់ខាងលើប្រាកដមែន ហើយដើមចោទឈ្មោះ [redacted] ម៉ារ៉ា បានសុំសិទ្ធិជាអ្នក



Scanned with
CamScanner

មានអំណាចមេបាលើកូនចំនួន ០២នាក់ តុលាការគប្បីសម្រេចតាមការទាមទាររបស់ដើមចោទ ស្របតាមមាត្រា ១០៣៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ។ ភាគីដែលមិនមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបាត្រូវបង្ករលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀតតាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៦- សោហ៊ុយចាំបាច់ក្នុងការចិញ្ចឹមបីបាច់ និងថែរក្សាកូន ដើមចោទមិនមានការទាមទារនោះទេ ដូចនេះ គប្បីតុលាការមិនពិចារណាត្រង់ចំណុចនេះឡើយ ។

៧- ប្រាក់ប្រដាប់ក្ដីគប្បីអនុវត្តតាមបញ្ញត្តិមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ហេតុដូច្នេះ តុលាការធ្វើការវិនិច្ឆ័យសេចក្ដីដូចខាងក្រោម ៖

<u>**សេចក្ដីសម្រេចបញ្ចប់**</u>

១- ឱ្យដើមចោទឈ្មោះ [redacted] ម៉ារ៉ាំ លែងលះពីចុងចម្លើយឈ្មោះ [redacted] វន ។

២- កំណត់ឱ្យដើមចោទឈ្មោះ [redacted] ម៉ារ៉ាំ ជាអ្នកមានអំណាចមេបាលើកូនចំនួន ០២នាក់៖

២.១- កូនទី១- ឈ្មោះ [redacted] គីមហួរ ភេទស្រី កើតថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ `មានសំបុត្របញ្ជាក់កំណើតលេខ ៣៤៥ សៀវភៅបញ្ជាក់កំណើតលេខ ០៤/២០១៨ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

២.២- កូនទី២ ឈ្មោះ [redacted] លីហ៊ុង ភេទប្រុស កើតថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ មានសំបុត្រកំណើតលេខ ៦៣ សៀវភៅកំណើតលេខ ០២/២០២២ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ ។

ភាគីដែលមិនមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែល មានអំណាចមេបា ត្រូវបង្ករលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀតតាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៣- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ ២០២៣ ។

ទុកសិទ្ធិប្ដឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

ថ្ងៃចន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្ដាល , ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

**ហត្ថលេខា និងត្រា**

**ចៅក្រម** [redacted]

---

**បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ៖**

ថ្ងៃចន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកណ្ដាល , ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣

បានឃើញ

ចៅក្រម

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner